# ការណែនាំរបៀបរៀបចំខ្លួន ដើម្បីធ្វើតែស្ត
## COLONOSCOPY ដោយប្រើថ្នាំបញ្ចុះ Golytely

ថ្ងៃណាត់ជួប : ____________________

ម៉ោងណាត់ជួប : ____________________

ទីកន្លែង : ____________________

### ធ្វើរបៀបទាំងនេះ ៧ថ្ងៃមុន ការពិនិត្យ :

- **រកអ្នកជូនដំណើរ :** គ្រូពេទ្យនឹងដាក់ថ្នាំឲ្យលោកអ្នកសំរាក និងសម្ងំ ដូច្នោះអ្នកមិនអាចបើកឡាន ឬជិះឡានសាធារណៈទៅផ្ទះបានទេ ។ បើអ្នកមកមន្ទីរពិនិត្យដោយគ្មានអ្នកជូនទេនោះ ការពិនិត្យរបស់អ្នកអាចនឹងត្រូវធ្វើការណាត់សាជាថ្មី ។
- ឈប់លេបថ្នាំជំនួយជាតិដែក (Iron) វីតាមីន E gingo ខ្ទឹ ថ្នាំអាស្ពារីន និងខ្ទឹមស ។
- បើអ្នកលេបថ្នាំ Coumadin ឬបើអ្នកមានជំងឺទឹកនោមផ្អែម សូមទូរស័ព្ទទៅគ្រូពេទ្យ ឬគិលានុបដ្ឋាយិការបស់អ្នកសំរាប់ការណែនាំពិសេស ។

↓

### ធ្វើរបៀបទាំងនេះ ៣ថ្ងៃមុន ការពិនិត្យ :

- បញ្ជាក់ឲ្យបានច្បាស់ជាមួយនិងអ្នកជូនដំណើររបស់អ្នក ។
- បើអ្នកត្រូវការលុបការណាត់ជួប សូមទូរស័ព្ទទៅគ្រូពេទ្យ ឬគិលានុបដ្ឋាយិការបស់អ្នក ។
- ពិនិត្យឡើងវិញនូវអាហារដែលត្រូវតមសំរាប់កំឡុងពេល ២ថ្ងៃក្រោយ ចូរគំរោងអាហាររបស់អ្នកតាមវិធីខាងក្រោមនេះ ។

↓

### ធ្វើរបៀបទាំងនេះ ២ថ្ងៃមុន ពិនិត្យមើល :

- ទទួលទានទឹកឲ្យបានយ៉ាងតិច ៨កែវក្នុងមួយថ្ងៃ ។
- ឈប់លេបថ្នាំព្យាបាលជម្ងឺរលាក ដូចជាថ្នាំ : Nuprin, Bufferin, Anacin, Advil, Motrin, Indocin, Voltran, Aleve, Ecotrin, Relafen, Alka Seltzer, Naprosyn, Voltaren *(Tylenol អាចលេបបាន)* ។
- ឈប់ញាំអាហារគ្រាប់ ពោតលីង គ្រាប់សណ្តែក និងធញ្ញជាតិផ្សេងៗ ។
- ហាមទទួលទានអាហាររឹងបន្ទាប់ពីម៉ោង ១២យប់ ។

### ធ្វើរបៀបទាំងនេះ ១ថ្ងៃមុន ពិនិត្យមើលៈ

- **ចាប់ផ្តើមគំរោងទទួលទានតែអាហាររាវថ្លាៗ ។** *បើអ្នកដាក់វត្ថុរាវក្នុងកែវថ្លាមួយ ហើយអ្នកអាចមើលឃើញធ្លុះ នោះអ្នកអាចទទួលទានបាន ។ អាហាររាវថ្លាមានដូចជា :*
  - ទឹកប៉ោម ទឹកទំពាំងបាយជូស និងទឹក cranberry
  - ស៊ុបមាន់ និងស៊ុបគោដែលថ្លាៗ
  - តែ និងកាហ្វេដោយមិនមានលាយទឹកដោះគោ ឬ ក្រែម
  - ទឹកសូដា Gatorade Kool-Aid និងសារាយ Jell–o មានរស់ជាតិផ្សេងៗ (ពណ៌អ្វីក៏បានលើកលែងតែពណ៌ក្រហម)
- **ជៀសវាង :** ទឹកខាប់ៗ ទឹកដោះគោ ក្រែម និងអាហាររឹង ។
- ចាក់ទឹកឲ្យពេញចូលក្នុងកំប៉ុងផ្លាស្ទិកដែលមានម្សៅថ្នាំបញ្ចុះ (Golytely) ក្រឡុកឲ្យបានសព្វរហូតដល់ម្សៅរលាយអស់ ហើយដាក់កំប៉ុងនោះនៅក្នុងទូរទឹកកក។
- **ម៉ោង 1:30 ថ្ងៃរសៀល** លេបថ្នាំ Metoclopramide ១គ្រាប់ជាមួយទឹក ។ ថ្នាំនេះជួយអ្នកកុំឲ្យរមួលពោះ ដែលបណ្តាលមកពីថ្នាំ Golytely ។
- **ម៉ោង 2:00 ថ្ងៃរសៀល** ចាប់ផ្តើមទទួលទានថ្នាំទឹកបញ្ចុះ (Golytely) ។ ទទួលទានម្តងមួយកែវពេញរៀងរាល់ ១៥នាទីរហូតទាល់តែអស់ ។ សូមខំប្រឹងទទួលទានម្តងមួយកែវពេញប្រសើរជាងម្តងបន្តិច ។
- **ម៉ោង 5:00 ល្ងាច** លេបថ្នាំ Metoclopramide គ្រាប់ទី២ ជាមួយទឹក ។
- **បន្តទទួលទានវត្ថុរាវពេញមួយថ្ងៃ ប៉ុន្តែកុំញាំអាហាររឹងឲ្យសោះ ។**
- ទឹកថ្នាំបញ្ចុះ Golytely នឹងបណ្តាលឲ្យអ្នកបត់ជើងធំញឹកញាប់ ។ យើងត្រូវការបែបនេះ ដើម្បីឲ្យពោះវៀនរបស់អ្នកទំនេរស្អាតសំរាប់ការពិនិត្យ ។ បើអ្នកមានបញ្ហាក្នុងការបញ្ចប់ការណែនាំនេះ សូមទូរស័ព្ទទៅគ្រូពេទ្យ ឬគិលានុបដ្ឋាយិការបស់អ្នក ។

↓

**<u>ធ្វើរបៀបទាំងនេះ នៅថ្ងៃ ពិនិត្យ :</u>**

- លេបថ្នាំដែលត្រូវលេបដូចធម្មតាជាមួយនឹងទឹកបន្តិច ។
- អ្នកអាចទទួលទានអាហាររាវរហូតដល់ ៣ម៉ោងមុនពេលពិនិត្យ ។
- នាំអ្នកជូនដំណើរ ឬអ្នកបើកឡានមកមន្ទីរពិនិត្យជាមួយអ្នកនៅថ្ងៃណាត់ ។
- អ្នកត្រូវមកដល់មន្ទីរពិនិត្យរោគ ៣០នាទីមុនម៉ោងណាត់ ។

តើអ្នកមានសំណួរ ឬបញ្ហាអំពីការណែនាំនេះ ឬទេ ? សូមទូរស័ព្ទទៅ : ______________________________ ។